**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ១៣ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៤ ៨៨៤,៣៦ ហិកតា នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ក្នុងនោះ កាត់ចេញពីតម្រប់ព្រៃឈើឆ្នាំ ២០០២ និងកាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន យូរីសាគរ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិ-បុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២០៦២ ខ.ពស ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់
- លិខិតលេខ ២៥០០ ខ.ពស ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៤ ៨៨៤,៣៦ ហិកតា ក្នុងនោះ (១) ទំហំ ១.២១២ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង (២) ទំហំ ៣.៦៧២,៣៦ ហិកតា កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន យូរីសាគរ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដែលមាន ទំហំ ៣.៩៨៥,៦៩ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៨៩៨,៦៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅឃុំសំរោង ស្រុកក្រវ៉ាញ ខេត្តពោធិសាត់ ស្ថិតក្នុងភូមិដូចដូចខាងក្រោម ៖

- ផ្ទៃដីសរុបទំហំ ២.៤៥៥,៦០ ហិកតា ក្នុងនោះ (១) ទំហំ ១.១៦២,៩៣ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង (២) ទំហំ ១២៩២,៦៧ ហិកតា កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុនយូរីសាគរ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ១៩២៩,២១ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៥២៦,៣៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃក១
- ផ្ទៃដីសរុបទំហំ ២.៤២៨,៧៦ ហិកតា ក្នុងនោះ (១) ទំហំ ៤៩,០៧ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង (២) ទំហំ ២៣៧៩,៦៩ ហិកតា កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន យូរីសាគរ ដែលមានទំហំ ២.០៥៦,៤៨ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៣៧២,២៨ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិតាជេះ

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ(១) និង (២) នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំសំរោង ស្រុកក្រវ៉ាញ ខេត្តពោធិ៍សាត់ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ២.១៥៨ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២.១១៥ ក្បាលដី ជូនប្រជាពលរដ្ឋ ១,០៦៣ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ៤៣ ក្បាលដី (ដីសាលារៀន ០១ក្បាលដី ដីទួលអ្នកតា ០១ ក្បាលដី ដីលានចាក់សំរាម ០១ ក្បាលដី និងដីបម្រុងទុករបស់រដ្ឋ ៤០ ក្បាលដី) នៅក្នុងភូមិដូចខាងក្រោម៖

- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ១.០៤១ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១.០១៨ ក្បាលដី ជូនប្រជាពលរដ្ឋ ៥៨៤ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ២៣ ក្បាលដី (ដីលានចាក់សំរាម ០១ ក្បាលដី និងដីបម្រុងទុករបស់រដ្ឋ ២២ ក្បាលដី) នៅ ភូមិព្រៃក ១
- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ១.១១៧ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១.០៩៧ ក្បាលដី ជូនប្រជាពលរដ្ឋ ៤៧៩ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ២០ ក្បាលដី (ដីសាលារៀន ០១ ក្បាលដី ដីទួលអ្នកតា ០១ ក្បាលដី និងដីបម្រុងទុករបស់រដ្ឋ ១៨ ក្បាលដី) នៅ ភូមិតាដេះ ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ(១)នៃអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០១៤**

**ស្តីពីការកាត់ដីទំហំ ៤៩៨៤.៣៦ ហិកតា នៅស្រុកភ្នំក្រវ៉ាញ ខេត្តពោធិ៍សាត់ ក្នុងនោះ កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន ឃុរីសាគរ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី**

តារាងនិយាមការចំណុចព្រំដី

Projection UTM, ZONE 48N, Datum WGS 84

| Point_ID | X | Y |
|---|---|---|
| 1 | 351141 | 1365274 |
| 2 | 351336 | 1365244 |
| 3 | 351346 | 1365010 |
| 4 | 351791 | 1365037 |
| 5 | 352118 | 1364911 |
| 6 | 353386 | 1364896 |
| 7 | 353598 | 1365002 |
| 8 | 353478 | 1365683 |
| 9 | 353386 | 1365793 |
| 10 | 353409 | 1365823 |
| 11 | 353646 | 1365604 |
| 12 | 353814 | 1365202 |
| 13 | 353988 | 1365064 |
| 14 | 354000 | 1364813 |
| 15 | 354290 | 1365200 |
| 16 | 354658 | 1365367 |
| 17 | 354887 | 1365388 |
| 18 | 355508 | 1365470 |
| 19 | 356501 | 1365833 |
| 20 | 359197 | 1366168 |
| 21 | 359022 | 1366530 |
| 22 | 359097 | 1366691 |
| 23 | 359371 | 1366644 |
| 24 | 359753 | 1366806 |
| 25 | 359842 | 1367155 |
| 26 | 360748 | 1367044 |
| 27 | 360909 | 1366644 |
| 28 | 360928 | 1366024 |
| 29 | 360857 | 1365545 |
| 30 | 360729 | 1365232 |
| 31 | 360565 | 1365399 |
| 32 | 360072 | 1365316 |
| 33 | 360112 | 1364742 |
| 34 | 359788 | 1365473 |
| 35 | 358905 | 1365130 |
| 36 | 357815 | 1364860 |
| 37 | 358302 | 1364104 |
| 38 | 358902 | 1364353 |
| 39 | 358820 | 1364713 |
| 40 | 359007 | 1364735 |
| 41 | 359027 | 1364427 |
| 42 | 359655 | 1364470 |
| 43 | 359661 | 1364735 |
| 44 | 359781 | 1364729 |
| 45 | 359796 | 1364530 |
| 46 | 359659 | 1364419 |
| 47 | 359668 | 1364260 |
| 48 | 359505 | 1363949 |
| 49 | 359615 | 1363900 |
| 50 | 359539 | 1363741 |
| 51 | 358815 | 1363688 |
| 52 | 358148 | 1363806 |
| 53 | 357992 | 1363319 |
| 54 | 358012 | 1363079 |
| 55 | 357731 | 1362730 |
| 56 | 357086 | 1362529 |
| 57 | 356409 | 1363065 |
| 58 | 355799 | 1363260 |
| 59 | 355108 | 1362961 |
| 60 | 354853 | 1363027 |
| 61 | 354889 | 1363112 |
| 62 | 354332 | 1363084 |
| 63 | 354070 | 1362877 |
| 64 | 353949 | 1362769 |
| 65 | 353881 | 1362603 |
| 66 | 353596 | 1362453 |
| 67 | 353674 | 1362320 |
| 68 | 353395 | 1362086 |
| 69 | 352936 | 1361986 |
| 70 | 352670 | 1361868 |
| 71 | 352494 | 1362032 |
| 72 | 352294 | 1361881 |
| 73 | 352266 | 1361790 |
| 74 | 352215 | 1361653 |
| 75 | 351946 | 1361502 |
| 76 | 351657 | 1361320 |
| 77 | 351364 | 1361790 |
| 78 | 351269 | 1361782 |
| 79 | 351139 | 1362765 |
| 80 | 350843 | 1363144 |
| 81 | 350695 | 1363523 |
| 82 | 350771 | 1363739 |
| 83 | 350899 | 1363991 |
| 84 | 350987 | 1364396 |
| 85 | 351259 | 1364569 |



ឧបសម្ព័ន្ធ(២)នៃអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០១៤

ស្តីពីការកាត់ដីទំហំ ៤៨៨៤.៣៦ ហិកតា នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ក្នុងនោះ កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង កាត់ចេញពីព្រៃសម្បទានក្រុមហ៊ុន យូរីសាគរ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

តារាងនិយាមការចំណុចព្រំដី

Projection UTM, ZONE 48N, Datum WGS 84

| Points_ID | X | Y |
|---|---|---|
| 1 | 354344 | 1363145 |
| 2 | 354731 | 1363097 |
| 3 | 354812 | 1362972 |
| 4 | 355157 | 1362914 |
| 5 | 355266 | 1362969 |
| 6 | 355301 | 1362788 |
| 7 | 355733 | 1362891 |
| 8 | 355744 | 1363088 |
| 9 | 355840 | 1363088 |
| 10 | 356050 | 1362948 |
| 11 | 356339 | 1362905 |
| 12 | 356657 | 1362775 |
| 13 | 356876 | 1362547 |
| 14 | 356980 | 1362438 |
| 15 | 357427 | 1362569 |
| 16 | 357681 | 1362618 |
| 17 | 357570 | 1362499 |
| 18 | 357169 | 1362200 |
| 19 | 357562 | 1362216 |
| 20 | 357661 | 1362141 |
| 21 | 357792 | 1361958 |
| 22 | 357863 | 1361687 |
| 23 | 357670 | 1361334 |
| 24 | 357699 | 1361007 |
| 25 | 357800 | 1360498 |
| 26 | 357968 | 1360485 |
| 27 | 357788 | 1359043 |
| 28 | 357264 | 1357536 |
| 29 | 357212 | 1357520 |
| 30 | 357021 | 1357189 |
| 31 | 356934 | 1357204 |
| 32 | 357287 | 1357879 |
| 33 | 357183 | 1357949 |
| 34 | 357337 | 1358625 |
| 35 | 356335 | 1358526 |
| 36 | 355884 | 1358562 |
| 37 | 354958 | 1359385 |
| 38 | 354066 | 1359506 |
| 39 | 353645 | 1359413 |
| 40 | 353354 | 1359165 |
| 41 | 353111 | 1359010 |
| 42 | 352332 | 1358861 |
| 43 | 352278 | 1358668 |
| 44 | 352081 | 1358558 |
| 45 | 351560 | 1358496 |
| 46 | 351544 | 1358214 |
| 47 | 351067 | 1357997 |
| 48 | 351011 | 1358044 |
| 49 | 350818 | 1357902 |
| 50 | 351015 | 1357805 |
| 51 | 351189 | 1357462 |
| 52 | 351196 | 1357316 |
| 53 | 350611 | 1356573 |
| 54 | 350682 | 1356348 |
| 55 | 350649 | 1356084 |
| 56 | 350558 | 1356086 |
| 57 | 350510 | 1355425 |
| 58 | 350297 | 1355396 |
| 59 | 350207 | 1355453 |
| 60 | 350197 | 1355594 |
| 61 | 350236 | 1355613 |
| 62 | 350176 | 1355915 |
| 63 | 350385 | 1356157 |
| 64 | 350300 | 1356395 |
| 65 | 350243 | 1356652 |
| 66 | 350291 | 1356754 |
| 67 | 350122 | 1357163 |
| 68 | 350178 | 1357340 |
| 69 | 350208 | 1357578 |
| 70 | 350239 | 1357594 |
| 71 | 350379 | 1357946 |
| 72 | 350457 | 1358304 |
| 73 | 350612 | 1358465 |
| 74 | 350927 | 1359100 |
| 75 | 351112 | 1359496 |
| 76 | 351078 | 1360392 |
| 77 | 351697 | 1360635 |
| 78 | 351669 | 1361462 |
| 79 | 351769 | 1361486 |
| 80 | 352326 | 1361921 |
| 81 | 352525 | 1362038 |
| 82 | 353006 | 1362049 |
| 83 | 353618 | 1362479 |
| 84 | 353620 | 1362518 |
| 85 | 353720 | 1362577 |
| 86 | 354099 | 1362875 |
| 87 | 354212 | 1362936 |
| 88 | 354341 | 1363110 |

